**បទអន្តរាគមន៍**

**ស្តីពី**

**គម្រោងផ្គត់ផ្គង់ទឹកជនបទ និងគម្រោងកែលម្អផ្លូវជនបទ ដំណាក់កាល ២**

**ក្រោមហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន**

**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ ២០២១ និងលើកទិសដៅការងារឆ្នាំ ២០២២**

**របស់ក្រសួងអភិវឌ្ឍន៍ជនបទ**

**ថ្ងៃ................ ខែ........... ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥**

**រាជធានីភ្នំពេញ ថ្ងៃទី ............. ខែ............ ឆ្នាំ ២០២១**

## ១. សេចក្តីផ្តើម

គម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទ ដំណាក់កាល ២ គឺជាគម្រោងក្រោមហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមការសម្របសម្រួល និងដឹកនាំដោយក្រសួងអភិវឌ្ឍន៍ជនបទ និងអនុវត្តការងារដោយក្រុមហ៊ុនរបស់ភាគីមិត្តចិន។

គម្រោងផ្គត់ផ្គង់ទឹកជនបទ ដំណាក់កាល ២ មានទឹកប្រាក់សរុប ៩០ ០២០ ០០០ RMB (ហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន) អនុវត្តដោយក្រុមហ៊ុន China Jiangxi International Economic and Technical Cooperation Co.,Ltd. នឹងធ្វើការជីកអណ្តូងស្នប់ចំនួន ៩៦៤អណ្តូង ជីកស្រះទឹកសហគមន៍ចំនួន ១២ស្រះ និងជីកស្រះទឹកសហគមន៍ដែលមានរៀបថ្មចំនួន ៤២ស្រះ នៅក្នុងខេត្តគោលដៅចំនួន ១០ រួមមាន ៖ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តកំពត ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម ដោយត្រូវអនុវត្តក្នុងរយៈពេល **២៤ខែ**។

ដោយឡែក គម្រោងកែលម្អផ្លូវជនបទ ដំណាក់កាល ២ មានទឹកប្រាក់សរុប **២៨៨ ៧០០ ០០០ RMB** (ហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតចិន) គម្រោងកែលម្អផ្លូវជនបទ ដំណាក់កាល ២ ត្រូវធ្វើការស្តារនីតិសម្បទាផ្លូវជនបទក្រាលកៅស៊ូ ប្រវែងសរុប ១១៩,៤៦៧ គ.ម. (មួយរយដប់ប្រាំបួនគីឡូម៉ែត្រ បួនរយហុកសិបប្រាំពីរម៉ែត្រ) ក្នុងខេត្តគោលដៅចំនួន ០៦ រួមមាន ៖ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តព្រៃវែងខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ ចែកជាពីរកញ្ចប់ (Lot) **ដែលកញ្ចប់ទី ១ (Lot I)** អនុវត្តដោយក្រុមហ៊ុន Shanghai Construction Group Co., Ltd. នឹងត្រូវធ្វើការសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ៧៩,១៣៧ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០៣ រួមមានខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តកណ្តាល និង**កញ្ចប់ទី ២ (Lot II)** អនុវត្តដោយក្រុមហ៊ុន

YUNNAN CONSTRUCTION AND INVESTMENT HOLDING GROUP CO., LTD. នឹងត្រូវធ្វើការសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ៤០,៤១ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០៣ រួមមានខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង ដោយត្រូវអនុវត្តក្នុងរយៈពេល **៣០ខែ**។

## ២. គោលបំណង

គម្រោងនឹងចូលរួមចំណែកធ្វើឲ្យមានលក្ខណៈប្រសើរឡើងដល់តម្រូវការប្រើប្រាស់ទឹក និងការធ្វើដំណើររបស់ប្រជាពលរដ្ឋរស់នៅ ក្នុងខេត្តគោលដៅរបស់គម្រោង ងាយស្រួលក្នុងការទទួលបានទឹកស្អាត និងទឹកសម្រាប់ធ្វើកសិកម្ម ព្រមទាំងធ្វើដំណោះរទៅកាន់ទីផ្សារ ងាយស្រួលស្វែងរកការងារធ្វើ ងាយស្រួលក្នុងការទទួលបានសេវាសង្គម និងផ្ដោតផងដែរទៅលើសុវត្ថិភាពសង្គម ភាពធន់នឹងអាកាសធាតុ និងប្រសិទ្ធភាពចំណាយលើការកែ លម្អបណ្ដាញផ្លូវជនបទដែលអាចឲ្យប្រជាពលរដ្ឋធ្វើដំណើរបានគ្រប់រដូវកាល នៅក្នុងតំបន់ដែលមាន វិសាលភាពកសិកម្មខ្ពស់នៃខេត្តគោលដៅ។

ក្រៅពីនេះគម្រោងក៏នឹងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌរស់នៅ សម្រាប់គ្រួសារនីមួយៗនៅជនបទ តាមរយៈការផ្គត់ផ្គង់ទឹកជនបទ និងការអភិវឌ្ឍផ្លូវជនបទ។

## ៣. សកម្មភាព និងរយៈពេលអនុវត្តគម្រោង

### ៣.១ គម្រោងផ្គត់ផ្គង់ទឹកជនបទ ដំណាក់ ២

គម្រោងផ្គត់ផ្គង់ទឹកជនបទ ដំណាក់ ២ នឹងត្រូវធ្វើការជីកអណ្ដូងស្នប់ចំនួន ៩៦៤អណ្ដូង ជីកស្រះទឹកសហគមន៍ចំនួន ១២ស្រះ និងជីកស្រះទឹកសហគមន៍ដែលមានរៀបថ្មចំនួន ៤២ស្រះ នៅក្នុងខេត្តគោលដៅចំនួន ១០ រួមមាន ៖ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តកំពត ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម ដោយត្រូវអនុវត្តក្នុងរយៈពេល ២៤ខែ។

### ៣.២ គម្រោងកែលម្អផ្លូវជនបទ ដំណាក់ ២

គម្រោងកែលម្អផ្លូវជនបទ ដំណាក់ ២ ត្រូវធ្វើការស្ដាបនាផ្លូវជនបទក្រាលកៅស៊ូ ប្រវែងសរុប ១១៩,៤៦៧ គ.ម. (មួយរយដប់ប្រាំបួនគីឡូម៉ែត្រ បួនរយហុបសិបប្រាំពីរម៉ែត្រ) ក្នុងខេត្តគោលដៅចំនួន ០៦ រួមមាន ៖ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកណ្ដាល ខេត្តព្រៃវែងខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ ដោយត្រូវអនុវត្តក្នុងរយៈពេល ៣០ខែ។

## ៤. អ្នកអនុវត្តគម្រោង

ក្រសួងអភិវឌ្ឍន៍ជនបទ។

## ៥. លទ្ធផលរំពឹងទុក

តាមរយៈនៃលទ្ធផលគម្រោងផ្គត់ផ្គង់ទឹកជនបទ និងគម្រោងកែលម្អផ្លូវជនបទ ដំណាក់ ២ ខាងលើ នឹងឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់ និងអាស្រ័យផលបានទាន់ ពេលវេលា និងគ្រប់រដូវកាល របស់បងប្អូនប្រជាពលរដ្ឋរស់នៅក្នុងខេត្តគោលដៅ របស់គម្រោង ព្រមទាំងចូលរួមលើកកម្ពស់កំណើនសេដ្ឋកិច្ចគ្រួសារបានសមរម្យ ពិសេសស្ត្រី នឹងទទួលបានការធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌនៃការរស់នៅ និងគុណភាពជីវិត ។

## ៦. លទ្ធផលសម្រេចបានក្នុងឆ្នាំ និងលទ្ធផលសម្រេចបានមកដល់បច្ចុប្បន្ន

### ក. គម្រោងផ្គត់ផ្គង់ទឹកជនបទ

អនុវត្តដោយក្រុមហ៊ុន China Jiangxi International Economic and Technical Cooperation Co.,Ltd. នឹងធ្វើការជីកអណ្តូងស្នប់ចំនួន ៩៦៤អណ្តូង ជីកស្រះទឹកសហគមន៍ចំនួន ១២ស្រះ និងជីកស្រះទឹកសហគមន៍ដែលមានរៀបថ្មចំនួន ៤២ស្រះ នៅក្នុងខេត្តគោលដៅចំនួន ១០ រួមមាន ៖ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តព្រៃវែង ខេត្តកំពត ខេត្តស្វាយរៀង ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម។

ជាលទ្ធផលគម្រោងជីកអណ្តូងបានចំនួន **៩៦៤** តម្លើងស្នប់បានចំនួន **៩៦៤** ជីកស្រះធម្មតាបានចំនួន **១២** និងស្រះមានរៀបថ្មបានចំនួន **៤២** ស្មើនឹងចំនួន **១០០% កាលពីថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ ២០២១ ហើយបានរៀបចំពិធីម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ ២០២១** នៅក្នុងភូមិអណ្តូងរវៀង ឃុំអញ្ចាញរូង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងឯកឧត្តម **ឡូ គួឈន** ទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់ស្ថានទូត នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

### ខ. គម្រោងកែលម្អផ្លូវជនបទ

គម្រោងកែលម្អផ្លូវជនបទ ជំហាន ២ ត្រូវធ្វើការស្ថាបនាផ្លូវជនបទក្រាលកៅស៊ូ ប្រវែងសរុប ១១៩,៤៦៧ គ.ម. (មួយរយដប់ប្រាំបួនគីឡូម៉ែត្រ បួនរយហុបសិបប្រាំពីរម៉ែត្រ) ក្នុងខេត្តគោលដៅចំនួន ០៦ រួមមាន ៖ ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកណ្តាល ខេត្តព្រៃវែងខេត្តស្វាយរៀង និងខេត្តត្បូងឃ្មុំ ចែកជាពីរកញ្ចប់ (Lot) រួមមាន ៖

១. **កញ្ចប់ទី ១ (Lot I) ៖** អនុវត្តដោយក្រុមហ៊ុន Shanghai Construction Group Co., Ltd. នឹងត្រូវធ្វើការសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ៧៩,១៣៧ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០៣ រួមមានខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងខេត្តកណ្តាល គិតត្រឹមបច្ចុប្បន្ន គម្រោងអនុវត្តន៍សម្រេចបាន **៩២,២៦%**។

២. **កញ្ចប់ទី ២ (Lot II) ៖** អនុវត្តដោយក្រុមហ៊ុន YUNNAN CONSTRUCTION AND INVESTMENT HOLDING GROUP CO., LTD. នឹងត្រូវធ្វើការសាងសង់ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ៤០,៤១ គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន ០៣ រួមមានខេត្តត្បូងឃ្មុំ ខេត្តព្រៃវែង និងខេត្តស្វាយរៀង គិតត្រឹមបច្ចុប្បន្ន គម្រោងអនុវត្តន៍សម្រេចបាន **៧១,៧៦%**។

## ៧. បញ្ហាប្រឈម

- ដោយសារបញ្ហាជំងឺកូវីដ ១៩ រីករាលដាលជាសកល ជាពិសេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ទឹកជំនន់រដូវវស្សាឆ្នាំ ២០២១ កន្លងមកនេះធ្វើឲ្យមានការខូចខាតផ្លូវ ស្ពាន និងសំណង់សិល្បៈការបន្ថែមទៀត។

## ៩. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីការងារគម្រោងផ្គត់ផ្គង់ទឹកជនបទ និងកែលម្អផ្លូវជនបទ ជំហាន ២ ដោយមើលឃើញអំពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានរបស់ប្រជាជននៅតំបន់ជនបទនូវផ្លូវជនបទ និងប្រភពទឹកស្អាត ហើយគម្រោងនឹងបន្តអនុវត្តជំហាន ៣ ទៀតដោយគ្រោងនឹងធ្វើការជីកអណ្តូងស្នប់ ចំនួន ១ ១១៥អណ្តូង ជីកស្រះទឹកសហគមន៍ចំនួន ៣៧ស្រះ និងជីកស្រះទឹកសហគមន៍ដែលមានរៀបថ្មចំនួន ៤០ស្រះ នៅក្នុងខេត្តគោលដៅចំនួន ០៨ រួមមាន ខេត្តប៉ៃលិន ឧត្តរមានជ័យ សៀមរាប ព្រះវិហារ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងខេត្តក្រចេះ ព្រមទាំងធ្វើការស្ថាបនាផ្លូវក្រាលកៅស៊ូពីរជាន់ ប្រភេទ DBST ប្រវែង ១៧៣,២១គីឡូម៉ែត្រ ស្ថិតនៅក្នុងខេត្តគោលដៅចំនួន ០៦ រួមមាន ខេត្តក្រចេះ មណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តសៀមរាប៕